ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

# គោលការណ៍ណែនាំស្ដីពី ការធានាគុណភាពការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា

# Quality Assurance Guidelines for Agricultural Extension in Cambodia




រៀបចំដោយ កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)
ឧបត្ថម្ភដោយ រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

IFAD
Investing in rural people

រាជធានីភ្នំពេញ ខែ វិច្ឆិកា ឆ្នាំ ២០១៨

# អារម្ភកថា

ការផ្សព្វផ្សាយកសិកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ទេរនូវចំណេះដឹង បច្ចេកវិទ្យា និងនវានុត្តន៍ថ្មីៗដែលធន់នឹងការប្រែប្រួលអាកាសធាតុ។ ការផ្សព្វផ្សាយនេះរួមចំណែកក្នុងការដោះស្រាយ គ្រោះធម្មជាតិ និងបញ្ហានានាដល់កសិករ និងសហគមន៍កសិកម្ម សំដៅជំរុញការបង្កើនផលិតភាព គុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងបង្កើនប្រាក់ចំណូលគ្រួសារ។

ឯកសារគោលការណ៍ណែនាំស្តីអំពី **ការធានាគុណភាពការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា** រៀបចំឡើងដោយអនុលោម តាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបង្ហាញថា ដើម្បីប្រសិទ្ធផលក្នុងការរៀបចំផែនការអនុវត្តគម្រោងផ្សព្វផ្សាយកសិកម្ម ដូចជាការអប់រំ បណ្តុះបណ្តាល និងផ្ទេរបច្ចេកទេស បច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗដល់កសិករ និងសហគមន៍កសិករដំដៅជំរុញបង្កើនផលិតភាពតាមតម្រូវការរបស់ពួកគាត់ និងពាណិជ្ជូបនីយកម្មកសិកម្មទទួលបានជោគជ័យ ជាចំបាច់ត្រូវពង្រឹងសមត្ថភាពនិងនិយ័តករ និងអ្នកផ្តល់សេវានានាឲ្យយល់ ប្រកាន់ និងអនុវត្តគោលការណ៍ធានាគុណភាពផ្សព្វផ្សាយ កសិកម្មមានលក្ខណៈស្តង់ដារ និងឯកភាពគ្នាហើយនឹងមានលក្ខណៈជំនាញ។ ទាំងនេះជាវិភាគទានដល់ការអភិវឌ្ឍប្រកបដោយភាពផ្លែផ្កា មានចីរភាព ធន់នឹងការប្រែប្រួលអាកាសធាតុ និងហានិភ័យនានាព្រមទាំងទីផ្សារ។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)បានរៀបចំ " **គោលការណ៍ណែនាំ ស្តីពីការធានាគុណភាពការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា** " នេះឡើងដើម្បីពង្រឹងសមត្ថភាពនិយ័តករ និងអ្នកផ្តល់សេវានានាឲ្យយល់ ប្រកាន់និងអនុវត្តគោលការណ៍ធានាគុណភាពផ្សព្វផ្សាយកសិកម្មមានលក្ខណៈស្តង់ដារ និងឯកភាពគ្នាហើយមានលក្ខណៈជំនាញ។

ឯកសារនេះបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម មកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង១១ខេត្តនៃកម្មវិធី សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលាប សាលាជាតិកសិកម្មកំពង់ចាម អគ្គនាយកដ្ឋានកសិកម្ម រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។

អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមដាក់ចេញនូវ " **គោលការណ៍ណែនាំស្តីពីការធានាគុណភាពការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា** " ដែលជាឯកសារគ្រឹះសម្រាប់មន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកទេសកសិកម្មថ្មីៗ វិធីសាស្ត្រ ការផ្លាស់ប្តូរនូវបទពិសោធន៍ ការចែករំលែកចំណេះដឹង និងនាំមកនូវកំណើនផលិតកម្មកសិកម្ម ជម្រុញឲ្យមានស្ថិរភាពសេដ្ឋកិច្ចគ្រួសារកសិករ សម្រួលដល់កសករក្នុងការសម្រួបខ្លួនតាមស្ថានភាពវិវត្តនៃសាកលភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម បន្សាំនិងការប្រែប្រួលអាកាសធាតុ រួមចំណែកក្នុងការផ្គត់ផ្គង់ផលិតផលកសិកម្មនៅលើទីផ្សារប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ សុក្រ ៨ រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...៣០.....ខែ..វិច្ឆិកា.....ឆ្នាំ២០១៨

**អគ្គនាយកដ្ឋានកសិកម្ម**

# សេចក្តីថ្លែងអំណរគុណ

ឯកសារស្តីពី "**ការធានាគុណភាពលើការងារផ្សព្វផ្សាយកសិកម្មនៅកម្ពុជា**" ត្រូវបានចងក្រងឡើងដោយមានការគាំទ្រនិងចង្អុលបង្ហាញយ៉ាងមុតមាំពី នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (GDA/DAE) លោកបណ្ឌិត ម៉ាក់ សឿន ប្រធានកម្មវិធីស្រាវជ្រាវនិងផ្សព្វផ្សាយនៃកម្មវិធី ASPIRE លោកបណ្ឌិត ម៉ៅ មីនា ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងលោក សាយ តុម ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

សូមថ្លែងអំណរគុណជាពិសេស ដល់ក្រុមការងារ សមាសភាពទី២ នៃកម្មវិធី ASPIRE ដែលបានផ្តល់អនុសាសន៍ ល្អៗ និងទាន់ពេលវេលា មានដូចជា លោកចាយ គង់គ្រុយ អនុប្រធានកម្មវិធី លោកប៉ូល ច័ន្ទរិទ្ធី ទីប្រឹក្សាផ្នែកគ្រប់គ្រងចំណេះដឹងផ្សព្វផ្សាយ និងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (ICT) អ្នកស្រី យឹម សំណាង ទីប្រឹក្សាផ្នែកផ្សព្វផ្សាយកសិកម្ម និងលោក យឹម សុខសុភាស់ ទីប្រឹក្សាផ្នែកត្រួតពិនិត្យ និងផ្តល់សុពលភាពលើសម្ភារៈផ្សព្វផ្សាយដែលមានស្រាប់។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD) ដែលបានសហការគាំទ្រផ្នែកហិរញ្ញវត្ថុដល់កម្មវិធី ASPIRE ជាពិសេសសម្រាប់ការពិគ្រោះយោបល់នេះ។

បើគ្មានការចូលរួម ពីសំណាក់ អស់លោក លោកស្រីខាងលើទេ ការរៀបចំគោលការណ៍ណែនាំស្តីពីការធានាគុណភាពនេះ ក៏មិនមានភាពងាយស្រួលដែរ ។ យើងសង្ឃឹមថា ឯកសារនេះនឹងរួមចំណែកលើកកំពស់គុណភាពការងារផ្សព្វផ្សាយកសិកម្មនៅកម្ពុជា និងបង្កើនសមត្ថភាពមន្ត្រីរបស់កម្មវិធី ASPIRE និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការផ្សព្វផ្សាយកសិកម្មនៅកម្ពុជាប្រកបដោយគុណភាពខ្ពស់។

ឯកសារនេះនៅតែស្ថិតក្នុងដំណាក់កាលសាកល្បង ហើយយើងខ្ញុំសូមស្វាគមន៍រាល់មតិយោបល់និងអនុសាសន៍ផ្សេងៗ។ សូមអធ្យាស្រ័យចំពោះការពាក្យពេចន៍ឬឃ្លាណាមួយមិនត្រឹមត្រូវ។

សូមអរគុណ។

អ្នកនិពន្ធ:

អ្នកនិពន្ធបង្គោល លោក ហួត ខៀវ khieu1967@gmail.com

អ្នកនិពន្ធចូលរួម លោក ឡូឌូវីស ផេមមី Ludovic_pommier@yahoo.com

សមាសភាពទី២ នៃកម្មវិធី ASPIRE ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

# មាតិកា


១. សេចក្តីផ្តើម ........ 1

១.១ បរិបទរួម ........ 1

១.២ មុខងារនៃការធានាគុណភាពផ្សព្វផ្សាយកសិកម្ម ........ 2

១.៣ ការប្រើប្រាស់គោលការណ៍ណែនាំ ........ 2

២. គោលបំណងនិងគោលការណ៍ជាគន្លឹះ ........ 3

២.១ គោលបំណង ........ 3

២.២ គោលការណ៍គន្លឹះនៃឯកសារនេះ ........ 4

៣. គោលការណ៍ណែនាំលើការធានាគុណភាព ........ 5

៣.១ ការធានាគុណភាពលើអ្នកផ្តល់សេវាសេវាផ្សព្វផ្សាយកសិកម្ម (QA-AESP) ........ 5

៣.១.១.លក្ខណៈសម្បត្តិ ........ 5

៣.១.២ ដំណើរការអនុវត្ត ........ 8

៣.១.៣ ការរៀបចំស្ថាប័ន ........ 10

៣.២.ការធានាគុណភាពសម្ភារៈផ្សព្វផ្សាយកសិកម្ម (QA-AEM) ........ 11

៣.២.១ លក្ខណៈសម្បត្តិ ........ 11

៣.២.២ ដំណើរការអនុវត្ត ........ 12

៣.២.៣ ការរៀបចំស្ថាប័ន ........ 18

៣.៣ ការធានាគុណភាពលើការវាយតម្លៃតម្រូវការកសិករ (QA-FNA) ........ 20

៣.៣.១ លក្ខណៈសម្បត្តិ ........ 20

៣.៣.២ ដំណើរការអនុវត្ត ........ 22

៣.៣.៣ ការរៀបចំរបស់ស្ថាប័ន ........ 24

៣.៤.ការធានាគុណភាពលើការវាយតម្លៃតម្រូវការទីផ្សារ (QA-MDA) ........ 24

៣.៤.១.លក្ខណៈសប្បត្តិ ........ 24

៣.៤.២ ដំណើរការអនុវត្ត ........ 26

៣.៤.៣ ការរៀបចំស្ថាប័ន ........ 27

៣.៥.ការធានាគុណភាពលើសកម្មភាពផ្សព្វផ្សាយកសិកម្ម (QA-AEA) ........ 27

៣.៥.១ លក្ខណៈសម្បត្តិ ........ 27

៣.៥.២ ដំណើរការអនុវត្ត ........ 28

៣.៥.៣ ការរៀបចំស្ថាប័ន ........ 29

៤.សន្និដ្ឋាន ........ 29

ឧបសម្ព័ន្ធ ........ 30

ឧបសម្ព័ន្ធទី ១: វាក្យស័ព្ទ និងពាក្យគន្លឹះពាក់ព័ន្ធនឹងការផ្សព្វផ្សាយកសិកម្ម ........ 30
ឧបសម្ព័ន្ធទី ២: ការធានាគុណភាពសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ........ 33
ទម្រង់ទី១: បញ្ជីពិនិត្យជ្រើសរើស អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ........ 33
ទម្រង់ទី២: តារាងបញ្ជីអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ........ 38
ទម្រង់ទី៣: ទម្រង់ការវាយតម្លៃការធានាគុណភាព សម្រាប់ជ្រើសរើស អ្នកផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្ម 40
ទម្រង់ទី៤: ទម្រង់ធានាគុណភាពការចុះកិច្ចសន្យា ........ 43
ទម្រង់ទី៥: ទម្រង់ការធានាគុណភាព សម្រាប់ប្រភេទគម្រោងដែលត្រូវផ្តល់ ........ 43
ឧបសម្ព័ន្ធទី ៣: ការធានាគុណភាពលើសម្ភារៈផ្សព្វផ្សាយកសិកម្ម ........ 46
ទម្រង់ទី១: ទម្រង់វាយតម្លៃការធានាគុណភាពសម្រាប់សម្ភារៈប្រភេទអត្ថបទ ........ 46
ទម្រង់ទី២: ទម្រង់វាយតម្លៃការធានាគុណភាពសម្រាប់សម្ភារៈផ្សព្វផ្សាយជាប្រភេទសម្លេង និង រូបភាព AV 47
ទម្រង់ទី៣: សូចនាករវាស់វែងសម្រាប់សម្ភារៈផ្សព្វផ្សាយទម្រង់ជាអត្ថបទ ........ 48
ទម្រង់ទី៤: សូចនាករវាស់វែងសម្ភារៈផ្សព្វផ្សាយទម្រង់ជា រូបភាពនិងសម្លេង ........ 50
ទម្រង់ទី៥: សូចនាករវាស់វែងលើមាតិកាបច្ចេកទេស ........ 50
ទម្រង់ទី៦: ធាតុសំខាន់ៗទាំង ៥ នៃភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និង ចេរភាព ........ 54
ទម្រង់ទី៧: សូចនាករវាស់វែងលើការអនុវត្តកសិកម្មវៃឆ្លាត និងអាកាសធាតុ ........ 56
ឧបសម្ព័ន្ធទី ៤: ការធានាគុណភាពនៃការវាយតម្លៃតម្រូវការកសិករ ........ 58
ទម្រង់ការធានាគុណភាពការវាយតម្លៃតម្រូវការកសិករ ........ 58
ឧបសម្ព័ន្ធទី ៥: ការធានាគុណភាពសម្រាប់ការវាយតម្លៃតម្រូវការទីផ្សារ ........ 60
ទម្រង់វាយតម្លៃការធានាគុណភាពសម្រាប់តម្រូវការទីផ្សារ ........ 60
ឧបសម្ព័ន្ធទី ៦: ការធានាគុណភាពលើសកម្មភាពផ្សព្វផ្សាយកសិកម្ម ........ 64
ទម្រង់វាយតម្លៃការធានាគុណភាពនៃសកម្មភាពផ្សព្វផ្សាយកសិកម្ម ........ 64
ឯកសារយោង ........ 68

# អក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| AEA | សកម្មភាពផ្សព្វផ្សាយកសិកម្ម |
| AE | ការផ្សព្វផ្សាយកសិកម្ម |
| AEAC | គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ |
| AEM | សម្ភារៈផ្សព្វផ្សាយកសិកម្ម |
| AESP | អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម |
| ASPIRE | កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| AV | សម្ភារៈផ្សព្វផ្សាយកសិកម្មជាសម្លេងនិងរូបភាព (ឧ. វីដេអូ) |
| AWD | អនុវត្តវិធីពន្លិចនិងបង្ហោកក្នុងដំណាក់កាលលូតលាស់ |
| AWPB | ផែនការការងារនិងថវិកាប្រចាំឆ្នាំ |
| CCCA | កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CEW | ភ្នាក់ងារផ្សព្វផ្សាយឃុំ |
| CSA | ការអនុវត្តកសិកម្មវៃឆ្លាត នឹងអាកាសធាតុ |
| DAE | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| Demo | ធ្វើបង្ហាញ |
| ESMQR | ការវាយតម្លៃគុណភាពត្រួតពិនិត្យសេវាផ្សព្វផ្សាយកសិកម្ម |
| EHCT | ក្រុមសម្របសម្រួលមជ្ឈមណ្ឌលបណ្តុំព័ត៌មានកសិកម្ម |
| F2F | ការរៀនសូត្រពីកសិករទៅកសិករ |
| FAO | អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ |
| FFS | សាលារៀនស្រែកសិករ |
| FFD | ទិវាបង្ហាញ |
| FNA | ការវាយតម្លៃតម្រូវការរបស់កសិករ |
| GAP | ការអនុវត្តកសិកម្មល្អ |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| GDP | ផលិតផលសរុបក្នុងស្រុក |
| ICT | បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ |
| ID | អត្តសញ្ញាណ (ប័ណ្ណក្រីក្រ) |
| IFAD | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម |
| IPM | វិធានការណ៍ចម្រុះការពារដំណាំ |
| KSA | ចំណេះដឹង ជំនាញ និងឥរិយាបថ |
| M & E | ការតាមដាននិងវាយតម្លៃ |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoE | ក្រសួងបរិស្ថាន |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ |
| MDA | ការវាយតម្លៃតម្រូវការទីផ្សារ |
| MOFA | ក្រសួងការបរទេស |

| | |
|---|---|
| MOI | ក្រសួងមហាផ្ទៃ |
| MTR | ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ |
| NATSC | អនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| PDAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត |
| PIM | សៀវភៅណែនាំលើការអនុវត្តកម្មវិធី |
| PRA | ការវាយតម្លៃជនបទដោយមានការចូលរួម |
| QA | ការធានាគុណភាព |
| QC | ការត្រួតពិនិត្យគុណភាព |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SLG | ក្រុមកសិករសិក្សាខ្នាតតូច |
| SME | សហគ្រាសធុនតូចនិងមធ្យម |
| STV | ពូជធន់និងអាកាសធាតុ |
| TOR | ក្រមប្រតិបត្តិដែលត្រូវអនុវត្ត |
| UN | អង្គការសហប្រជាជាតិ |
| URL | ទីតាំងធនធានសកល |
| WB | ធនាគារពិភពលោក |
| US$ | រូបិយប័ណ្ណអាមេរិក |

# ១. សេចក្តីផ្តើម

## ១.១ បរិបទរួម

នៅឆ្នាំ ២០១៥ ប្រទេសកម្ពុជាមានប្រជាជនសរុបចំនួន ១៥.៣ លាននាក់ ជាមួយកំណើនប្រជាជន ១.៦% ក្នុងមួយឆ្នាំ (BTI, ២០១៦) ។ ប្រជាជនកម្ពុជាជិត ៨០% (ពោលគឺប្រហែលជាង ២លានគ្រួសារ) រស់នៅតាមតំបន់ជនបទដែលទាញប្រយោជន៍ពីដីកសិកម្មចំនួន៣៩%សម្រាប់ការងារជាំដុះ (របាយការណ៍ឆ្នាំ២០១៤)។ ដូច្នេះហើយវិស័យកសិកម្មរួមចំណែកយ៉ាងសំខាន់ដល់ផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជា (GDP) ចំនួន ៣៧% (ផ្អែកតាមរបាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០១៥) ដែលអាចនឹងឈានដល់ជាង ២០ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៦ (BTI, 2016) ។

ដើម្បីបន្តថែរក្សា និងបង្កើនកំណើនផលិតផលក្នុងស្រុកសរុបតាមរយៈការផ្លាស់ប្តូរពីកសិកម្មបែបចិញ្ចឹមជីវិតឆ្ពោះទៅរកបែបធ្វើពាណិជ្ជកម្មវិញនោះ។ដូចនេះ ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ដើរតួនាទីជាកាតាលីករដ៏សំខាន់រួមចំណែកដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម ។

ការវិវត្តន៍នេះ ត្រូវបានរួមចំណែកពីតួអង្គសំខាន់ៗជាច្រើនពីផ្នែកសាធារណៈ និងឯកជន ដែលតួអង្គនីមួយៗមានវិធីសាស្ត្រនិងបទដ្ឋានរៀងៗខ្លួន ដែលក្នុងនោះក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទមានតួនាទីសំខាន់ក្នុងការដាក់ចេញនូវគោលនយោបាយពាក់ព័ន្ធ ផែនការយុទ្ធសាស្ត្រ ការអនុវត្តជាបទដ្ឋាន ឧបករណ៍និងបច្ចេកទេសសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ជាពិសេសអនុលោមតាមគោលការណ៍ណែនាំទាំងប្រាំនៃការធានាស្តង់ដារគុណភាព (សូមមើលរូបភាពទី១) ។




**រូបភាពទី១: មុខងារចម្បងនៃការធានាគុណភាព**

គោលការណ៍ណែនាំទាំងប្រាំនេះ នឹងដើរតួជាអ្នកចង្អុលបង្ហាញសម្រាប់ពង្រឹងសមត្ថភាពរៀបចំផែនការ និងអនុវត្តការផ្សព្វផ្សាយកសិកម្មប្រកបដោយនវានុវត្តន៍មានភាពធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ និងឆ្លើយតបនឹងតម្រូវការទីផ្សារ។ ការយល់ដឹងពីវាក្យស័ព្ទនិងពាក្យនីមួយៗនៅក្នុងឯកសារការធានាគុណភាព គឺជាមូលដ្ឋានចាំបាច់មួយដើម្បីអនុវត្តឲ្យមានប្រសិទ្ធិភាព(**ឧបសម្ព័ន្ធទី ១**)។

ស្របនឹងបរិបទនេះ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម ដែលជាអង្គភាពក្រោមបង្គាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានការឧបត្ថម្ភហិរញ្ញវត្ថុពី IFAD មានកាតព្វកិច្ចរៀបចំ

គោលនយោបាយ យុទ្ធសាស្ត្រ និងឧបករណ៍នានា។ គោលការណ៍ណែនាំនេះ និងគាំទ្រដល់ការរៀបចំផែនការនិងការអនុវត្តការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធិផល។

ដើម្បីសម្រេចបាននូវលទ្ធផលដ៏ធំធេងនៃក្របខណ្ឌគោលនយោបាយផ្សព្វផ្សាយកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាការចាំបាច់ណាស់ដែលយើងត្រូវបង្កើនសមត្ថភាពអង្គភាពនិយ័តករទាំងនៅថ្នាក់កណ្តាល និងថ្នាក់ខេត្តជាមុនសិន បន្ទាប់មកលើកកម្ពស់ការយល់ដឹង លើការធានាគុណភាពដល់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម វាពិតប្រាកណាស់ហើយថា នៅក្នុងអំឡុងពេលនៃការអនុវត្ត បញ្ហាប្រឈមខ្លះៗពិតជាមានដូចជាកង្វះខាតធនធានមនុស្សនិងហិរញ្ញវត្ថុនៅដំណាក់កាលដំបូង ដែលចាំបាច់ត្រូវបន្តគិតគូរនិងដោះស្រាយពេញមួយវដ្តជីវិតគម្រោង។ ផ្អែកតាមការអនុវត្តនិងមេរៀនបទពិសោធន៍ គោលការណ៍ណែនាំលើការធានាគុណភាពទាំងនេះគួរដាក់បញ្ចូលបន្ថែមដោយធ្វើយ៉ាងណាឲ្យមានការឆ្លើយតបទៅនឹងគ្រប់លក្ខខណ្ឌកំណត់ទាំងអស់។

## ១.២ មុខងារនៃការធានាគុណភាពផ្សព្វផ្សាយកសិកម្ម

គោលការណ៍ណែនាំការធានាគុណភាព នេះគឺជាការអនុវត្តការផ្សព្វផ្សាយដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា អាចថាពេលខ្លះមានវិធីសាស្ត្រ និងវិសាលភាពខុសៗគ្នាក៏ដោយ ប៉ុន្តែជាទូទៅវាបានគូសបញ្ជាក់និងផ្តល់នូវនីតិវិធីគំនិតនិងការវាយតម្លៃ ឆ្ពោះទៅរកលទ្ធផលដែលចង់បាន ដូច្នេះហើយតួអង្គសំខាន់ៗទាំងអស់ដែលប្រតិបត្តិការងារសេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ទោះបីគេមានប្រភពថវិកាឯករាជ្យក្តី ពួកគេគួរស្វែងយល់និងអនុវត្តដំណើរការវាយតម្លៃការធានាគុណភាព ឲ្យមានលក្ខណៈជាប្រព័ន្ធនិងនៅគ្រប់ដំណាក់កាលនីមួយៗនៃវដ្តរបស់គម្រោង។ លើសពីនេះទៀត ក្នុងសមត្ថភាពនាអនាគតរបស់និយ័តករ (ឧទា.នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ) ដែលជាសេនាធិការឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងទទួលបាននូវបទពិសោធន៍និងមេរៀននៃការអនុវត្តគោលការណ៍នៃការធានាគុណភាពនេះ តួនាទី របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម គួរជាអ្នកត្រួតពិនិត្យគុណភាព (Quality Controller [QC]) ។ កិច្ចការនេះអាចទទួលជោគជ័យគួរតែមានបទដ្ឋានគតិយុត្តក្រោមច្បាប់ ដូចជាសេចក្តីប្រកាសឬលិខិតផ្សេងៗដែលមានតម្លៃប្រហាក់ប្រហែលនឹងចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងកិច្ចសហការពី អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ទាំងអស់ឲ្យចុះបញ្ជីឈ្មោះស្ថាប័ន ឬ អង្គការនៅ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដើម្បីធានាដល់ការអនុវត្តគោលការណ៍ការធានាគុណភាពនេះឲ្យមានប្រសិទ្ធភាពនិងចីរភាព។

គោលដៅចម្បងនៃគោលការណ៍ណែនាំការធានាគុណភាព នេះគឺដើម្បីផ្តល់នូវគំនិតទស្សនៈទានជម្រើសឬការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយគុណភាពដល់អង្គភាពនិយ័តករនិង អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ដើម្បីជួយពួកគេក្នុងការធ្វើផែនការនិងអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្មប្រកប ដោយប្រសិទ្ធិភាពនិងប្រសិទ្ធិផល បើទោះយ៉ាងនេះ វាជាមុខងារផ្ទៃក្នុងរបស់អង្គភាពនិយ័តកម្ម និងបុគ្គលិករបស់ខ្លួន ដើម្បីធានាថាការអនុវត្តរបស់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម គឺសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរ។

ប្រសិនបើគោលការណ៍ណែនាំនេះ ត្រូវបានចែកចាយបានយ៉ាងល្អនោះវានឹងជួយពន្លឿនការអនុវត្តកម្មវិធីហើយនឹងមិនត្រឹមតែជួយកសិករឲ្យមានការយល់ដឹង មានទំនុកចិត្ត មានសមត្ថភាពក្នុងការដោះស្រាយបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយផ្លាស់ប្តូរឥរិយាបថរបស់ពួកគេឲ្យទទួលយកនិងចែករំលែកចំណេះដឹង និងបទពិសោធន៍ពីការអនុវត្តកសិកម្មថ្មីយ៉ាងឆាប់រហ័សទៅដល់កសិករដទៃទៀតទាំងនៅក្នុង និងក្រៅសហគមន៍របស់ពួកគេដោយស្ម័គ្រចិត្ត។

## ១.៣ ការប្រើប្រាស់គោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះ ជាឯកសារ/អំណះអំណាងចង្អុលបង្ហាញពីលំហូរសកម្មភាពក្នុងកិច្ចដំណើរការតាមទម្លាប់ ឬការអនុវត្តន៍ដ៏ត្រឹមត្រូវមួយ។ គោលការណ៍ណែនាំស្តីពីការធានាគុណភាពការងារផ្សព្វផ្សាយកសិកម្ម ត្រូវបាន

ដាក់ចេញ ហើយអង្គភាពនិយ័តកររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទាំងនៅថ្នាក់កណ្តាលនិងថ្នាក់ខេត្ត និង អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម គួរប្រើគោលការណ៍ណែនាំសម្រាប់រៀបចំផែនការនិងសកម្មភាពសម្រាប់ការវាយតម្លៃលទ្ធផលការផ្សព្វផ្សាយកសិកម្មឲ្យមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ គោលការណ៍ណែនាំនីមួយៗមានគោលបំណងជាក់លាក់របស់ខ្លួន ពេលវេលានិងតួអង្គសំខាន់ខុសៗគ្នា ក្នុងការប្រើប្រាស់គោលការណ៍ណែនាំនេះ។

**គោលការណ៍ណែនាំទី១** គឺពាក់ព័ន្ធទៅនឹងការធានាគុណភាពសម្រាប់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ជំហានសំខាន់ៗចំនួន ៣ គួរតែត្រូវបានពិចារណាឲ្យបានដិតដល់ (១) ដំណាក់កាលរៀបចំ (២) ដំណាក់កាលជ្រើសរើស និង (៣) ដំណាក់កាលអនុវត្ត។ នៅក្នុងដំណាក់កាលដំបូងនៃវដ្តគម្រោង វាចាំបាច់ណាស់ដែលកម្មវិធីត្រូវបង្កើតគណៈកម្មាធិការជ្រើសរើសមួយ និង/ឬមន្ត្រីទទួលខុសត្រូវដែលជាតំណាងមកពីអង្គភាពផ្សេងៗ ដូចជាលទ្ធកម្ម/ធនធានមនុស្ស និងមន្ត្រីកម្មវិធីដើម្បីបំពេញសកម្មភាពទាំងនេះ។ ចំណែកឯការវាស់ស្ទង់លទ្ធផលអនុវត្តរបស់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម កម្មវិធីអាចចាត់តាំងក្រុមមនុស្ស ២-៣ នាក់ដើម្បីធ្វើការវាយតម្លៃលទ្ធផលនៅអំឡុងពេលឬនៅពេលបញ្ចប់គម្រោង ដោយផ្អែកលើសូចនាករ។ លទ្ធផលពីការវាយតម្លៃអាចប្រាប់ដល់កម្មវិធីថាតើអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្ម អនុវត្តភារកិច្ចរបស់ខ្លួនបានកម្រឹតណា " ល្អខ្លាំងណាស់ ខ្សោយ" ។ល។

**គោលការណ៍ណែនាំទី២** ដែលមានបង្ហាញនៅក្នុងឯកសារនេះ គឺពិពណ៌នាអំពីដំណើរការអនុវត្ត និងរបៀបវាយតម្លៃគុណភាពសម្ភារៈផ្សព្វផ្សាយកសិកម្ម មានស្រាប់ដែលនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មប្រមូលបានក្នុងរយៈកាលកន្លងមក ។ គោលការណ៍ណែនាំនេះក៏អាចត្រូវបានប្រើសម្រាប់អ្នកដែលចង់បង្កើតសម្ភារៈផ្សព្វផ្សាយកសិកម្មថ្មី ស្របទៅនឹងតម្រូវការថ្មីផងដែរ។

**គោលការណែនាំទី៣** ពាក់ព័ន្ធទៅនឹងការវាយតម្លៃលើតម្រូវការរបស់កសិករ ដែលរៀបរាប់អំពីការកំណត់និងចាត់អាទិភាពលើតម្រូវការរបស់កសិករ។ សកម្មភាពនេះ គួរត្រូវបញ្ចប់នៅដំណាក់កាលដំបូងនៃការអនុវត្តគម្រោង ជាពិសេសក្រោយការចុះកិច្ចសន្យា។ ប្រសិនបើគ្មានការវាយតម្លៃតម្រូវការរបស់កសិករទេ នោះវានឹងពិបាកក្នុងការកំណត់ពីកិច្ចការអ្វីដែលត្រូវធ្វើ និងថាតើត្រូវផ្តល់ដំណោះស្រាយដល់កសិករអ្វីខ្លះ។

**គោលការណ៍ណែនាំទី៤** គឺពាក់ព័ន្ធនឹងការវាយតម្លៃតម្រូវការទីផ្សារ ពោលគឺការប្រមូលទិន្នន័យនិងព័ត៌មាននៃការផ្គត់ផ្គង់និងតម្រូវការទីផ្សារ រួមទាំងផ្នែកហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសង្គម។ កិច្ចការនេះគួរតែត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តគម្រោង និងមិនត្រូវប្រើប្រាស់វាត្រឹមតែជាព័ត៌មានដើមគ្រាប់ណ្ណោះទេ ប៉ុន្តែក៏ជាមូលដ្ឋាននៃសំណើសុំសកម្មភាពផ្សព្វផ្សាយ ដើម្បីបំពេញគម្លាតទីផ្សារលើវិស័យអាទិភាពដូចជាដំណាំដែលមានតម្លៃខ្ពស់ ចិញ្ចឹមសត្វ និងផលិតផលកសិកម្មផ្សេងទៀត ហើយត្រូវមានផលប៉ះពាល់តិចបំផុតលើបរិស្ថាន/ធនធានធម្មជាតិ រួមទាំងបញ្ហាសង្គមនិងវប្បធម៌។

**គោលការណ៍ណែនាំចុងក្រោយ** គឺពាក់ព័ន្ធនឹងសកម្មភាពផ្សព្វផ្សាយកសិកម្ម ដែលពិពណ៌នាអំពីវិធីសាស្ត្រសកម្មដែលបានជ្រើសរើស (ដូចជា ក្រុមកសិករសិក្សាខ្នាតតូច កសិដ្ឋាន/ស្រែបង្ហាញ ទិវាបង្ហាញ ជាដើម) ដើម្បីផ្លាស់ប្តូរ/បញ្ជូនសារកសិកម្មទៅកសិករ។ យើងអាចវាយតម្លៃសកម្មភាពនេះបានអំឡុងពេល និងក្រោយពេលគម្រោងបញ្ចប់។

# ២. គោលបំណងនិងគោលការណ៍ជាគន្លឹះ

## ២.១ គោលបំណង

គោលបំណងរួមនៃឯកសារនេះ គឺដើម្បីណែនាំដល់អង្គភាពនិយ័តករ និងមន្ត្រីរបស់ខ្លួនអំពីរបៀបត្រួតពិនិត្យ និងធានាគុណភាពនៃការផ្សព្វផ្សាយកសិកម្មនៅក្នុងប្រទេសកម្ពុជា។ គោលការណ៍ណែនាំនេះក៏នឹងជួយដល់អ្នកផ្តល់